ភ្នំពេញ, ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៦

**ប្រកាសលេខ: ៣២៩ អយក.ប្រក**

**ស្ដីពីការប្ដូរឈ្មោះវិទ្យាល័យ តាកែវ ទៅជា វិទ្យាល័យ**

**"ជា ស៊ីម– តាកែវ" ក្នុងខេត្តតាកែវ**

* * *

**រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា**

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេច **នរោត្ដម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ១៩៩៤
- បានឃើញក្រឹត្យ–ច្បាប់លេខ៣០ ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ១៩៨៦ ស្ដីពីប្រព័ន្ធអប់រំទូទៅ
- យោងលិខិតរបស់សមាគមមាតាបិតាសិស្សទ្រទ្រង់ វិទ្យាល័យ តាកែវ ចុះថ្ងៃទី ២៧ កុម្ភៈ ១៩៩៦ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំយុវជន និង កីឡា និង អភិបាលខេត្តតាកែវ
- តាមយោបល់ឯកភាពរបស់ សម្ដេច **ជា ស៊ីម**

**សំរេច**

**ប្រការ ១** : អនុញ្ញាតអោយប្ដូរឈ្មោះវិទ្យាល័យតាកែវ បច្ចុប្បន្នទៅជា"វិទ្យាល័យ **ជា ស៊ីម**–តាកែវ" ចាប់ពីឆ្នាំសិក្សា ១៩៩៥–៩៦ តទៅ ។

**ប្រការ ២**: បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៣** : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅនិងមត្តេយ្យសិក្សា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជននិងកីឡា

ប្រធានមន្ទីរ អប់រំយុវជននិងកីឡា ខេត្តតាកែវ និង នាយកវិទ្យាល័យ ខាំ ស៊ីម តាកែវ មានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**គា សាហាន**

* * *

ភ្នំពេញ, ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៦

**ប្រកាសលេខ: ៣៣០ អយក.ប្រ.ក**

**ស្តីពីការប្តូរឈ្មោះ សាលាបឋមសិក្សា ចំនួ សារុន ស្តៅខ្មែ**

* * *

**រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១-១១-៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០-៧-១៩៩៤
- បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រ.ច ចុះថ្ងៃទី ២០-១១-៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ
- បានពិនិត្យលិខិតស្នើសុំរបស់មន្ទីរអប់រំ យុវជន និង កីឡាខេត្តតាកែវលេខ ១៥៦៩ អយកត.បឋម ចុះថ្ងៃទី ២២-៣-៩៦ ដោយមានចំណារឯកភាពរបស់អភិបាលខេត្ត រងទី ២ លេខ ៤៧៣ លខ.បជ ចុះថ្ងៃទី ២២-៣-៩៦
- តាមយោល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា